**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ០០៨ **គ.ជ.ប.** ស.ជ.ណ

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នៅតាមគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) ចំនួន ១៩៨រូប ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាម គ.ក.ប/គ.ក.រ នៃរាជធានី ខេត្ត របស់ភូមិភាគនីមួយៗ ទូទាំងប្រទេស សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធាន | ចំនួន ១ រូប |
| ២- អនុប្រធាន | ចំនួន ១ រូប |
| ៣- លេខាធិការ | ចំនួន ១ រូប |
| ៤- សមាជិកទី១ | ចំនួន ១ រូប |
| ៥- សមាជិកទី២ | ចំនួន ១ រូប |
| ៦- សមាជិកទី៣ | ចំនួន ១ រូប។ |

សាធារណជន ដែលមានបំណងដាក់ពាក្យសុំចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំចូលបម្រើការងារ នៅរៀងរាល់ម៉ោងធ្វើការ នៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប អាសយដ្ឋាន (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្តីជូនដំណឹងនេះ។

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ (វេលាម៉ោង ៧:០០ នាទីព្រឹក)។
- ការឈប់ទទួលពាក្យ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៤ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។/.

ថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២៤

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ប្រាជ្ញ ចន្ទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០៩ គ.ជ.ប.ស.ជ.ណ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## លក្ខខណ្ឌនៃការជ្រើសរើស និងភារកិច្ចរបស់ សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នៅតាមគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ.ខប) ទាំង២៥ ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) សរុបចំនួន **១៩៨ រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃរាជធានី ខេត្ត របស់ភូមិភាគនីមួយៗ ទូទាំងប្រទេស ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធាន | ចំនួន ១ រូប |
| ២- អនុប្រធាន | ចំនួន ១ រូប |
| ៣- លេខាធិការ | ចំនួន ១ រូប |
| ៤- សមាជិកទី១ | ចំនួន ១ រូប |
| ៥- សមាជិកទី២ | ចំនួន ១ រូប |
| ៦- សមាជិកទី៣ | ចំនួន ១ រូប ។ |

## I- លក្ខខណ្ឌទូទៅសម្រាប់ការជ្រើសរើសសមាសភាព គ.ក.ប/គ.ក.រ ÷

- ជាប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការដែលរស់នៅក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត
- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានបទពិសោធន៍ការងារពាក់ព័ន្ធ
- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិតឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុងគណៈកម្មការតែមួយ

- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសុខភាពល្អ
- មានលទ្ធភាពបំពេញការងារពេញម៉ោង
- មិនមែនជាកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ ឬជំនួយការមេភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ប្រធាន អនុប្រធាន លេខាធិការ និងសមាជិក គ.ក.ប/គ.ក.រ ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងត្រូវលាលែងបណ្តោះអាសន្នពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារ រហូតដល់ថ្ងៃចប់ភារកិច្ច
- បេក្ខនារី ឬ បេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត។

## II- ភារកិច្ចទទួលខុសត្រូវរបស់សមាសភាព គ.ក.ប/គ.ក.រ ត្រូវបានកំណត់ដូចខាងក្រោម ÷

គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែល គ.ក.ប/គ.ក.រ នោះ ទទួលខុសត្រូវស្របតាមច្បាប់បោះឆ្នោត បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការណែនាំរបស់ គ.ជ.ប ។ សមាសភាព គ.ក.ប/គ.ក.រ នីមួយៗ មានការទទួលខុសត្រូវ និងភារកិច្ចរួមដូចខាងក្រោម ៖

១- ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

២- អនុប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចជាជំនួយការរបស់ប្រធាន គ.ក.ប/គ.ក.រ ទទួលខុសត្រូវក្នុងការផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនៅពេលបោះឆ្នោត និងកត់ត្រាសម្លេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

៣- លេខាធិការ មានភារកិច្ចទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៤- សមាជិកទី១ មានភារកិច្ចទទួលខុសត្រូវពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

៥- សមាជិកទី២ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖

- ជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត
- ចាត់ចែងសណ្តាប់ធ្នាប់ជូនអ្នកបោះឆ្នោត
- ចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើ ដើម្បីធ្វើមោឃភាព
- បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២) នៅមុខការិយាល័យបោះឆ្នោត
- បញ្ជូនស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងស្រោមសំបុត្រដាក់បញ្ជីវត្តមាន អ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅគធ.ឃប បន្ទាប់ពីបញ្ចប់ការធ្វើកំណត់ហេតុនៃការរាប់ សន្លឹកឆ្នោត (ទ.១១០២)។

៦- សមាជិកទី៣ មានភារកិច្ចទទួលខុសត្រូវការងារសណ្តាប់ធ្នាប់ របៀបរៀបរយ និងថែរក្សាសម្ភារឯកសារបោះឆ្នោតនៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

## III- វិញ្ញាសាដែលត្រូវសម្ភាសន៍

- សំណួរចំណេះដឹងទូទៅទាក់ទងនឹងការបោះឆ្នោត (ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា) មានចំនួនមួយសំណួរ។
- សំណួរសម្ភាសន៍ទាក់ទងនឹងមុខតំណែង (បទពិសោធន៍លើរបៀបធ្វើការងារពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ) មានចំនួនពីរសំណួរ។

## IV- រយៈពេលបម្រើការងារចំនួន ៤ថ្ងៃកន្លះ

- ចូលរួមវគ្គបណ្តុះបណ្តាល ២ថ្ងៃ ពីថ្ងៃទី២២ ដល់ថ្ងៃទី២៣-២-២០២៤
- ទទួល និងត្រួតពិនិត្យសម្ភារ ឯកសារ និងត្រៀមរៀបចំការិយាល័យបោះឆ្នោត ១ថ្ងៃ (ថ្ងៃទី២៤-២-២០២៤)
- ចាត់ចែងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១ថ្ងៃ (ថ្ងៃទី២៥-២-២០២៤)
- ការប្រគល់សម្ភារ ឯកសារជូន គធ.ឃប មួយព្រឹក (ថ្ងៃទី២៦-២-២០២៤)។

V- ប្រាក់កម្រៃម៉ោការសរុប

| | | |
|---|---|---|
| - ប្រធាន | ប្រាក់កម្រៃទទួលបាន | ៣១៥.០០០ រៀល |
| - អនុប្រធាន | ប្រាក់កម្រៃទទួលបាន | ២៩២.៥០០ រៀល |
| - លេខាធិការ | ប្រាក់កម្រៃទទួលបាន | ២៧០.០០០ រៀល |
| - សមាជិកទី១ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល |
| - សមាជិកទី២ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល |
| - សមាជិកទី៣ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល ។ |

VI- ទំនាក់ទំនងព័ត៌មាន

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើ សូមអញ្ជើញមកទំនាក់ទំនងព័ត៌មាន ឬមើលសេចក្តីជូនដំណឹងនៅលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ។

VII- កាលបរិច្ឆេទនៃការទទួលពាក្យ និងធ្វើសម្ភាសន៍

ការទទួលពាក្យសុំចូលបម្រើការងារនឹងធ្វើនៅតាម លគធ.ខប នីមួយៗ ៖

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ (វេលាម៉ោង ៧:០០ ព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៤ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវធ្វើសម្ភាសន៍ ចន្លោះពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅតាម លគធ.ខប
- ការធ្វើសម្ភាសន៍នៅតាម លគធ.ខប ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤។

VIII- ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បន្ទាប់ពីការចែកពាក្យ និងទទួលពាក្យរួច គណៈកម្មការជ្រើសរើស ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជន និងត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនដែលមានលក្ខខណ្ឌល្អជាងគេ ៣រូបសម្រាប់មួយមុខតំណែង ដើម្បីមកសម្ភាសន៍។ សំណុំលិខិតរបស់បេក្ខជនមិនត្រូវប្រគល់ជូនវិញទេ។

IX- លទ្ធផលនៃការធ្វើសម្ភាសន៍

លទ្ធផលនៃការធ្វើសម្ភាសន៍នឹងបិទផ្សាយនៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។

**<u>បញ្ជាក់បន្ថែម</u>** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮ យ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែងថា «... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល »
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**